**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**លេខៈ បព ៧១/២០២៥ កបទ.សអ**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំលើកទី២១ របស់គណៈកម្មការចម្រុះ កម្ពុជា-វៀតណាម ស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សៀមរាប ថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៥

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម ឡេ ហ័យជុង** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានអញ្ជើញធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំលើកទី២១នៃគណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (JC លើកទី២១) នៅខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា។

ក្នុងអំឡុងពេលស្នាក់នៅកម្ពុជា **ឯកឧត្តម ឡេ ហ័យជុង** បានអញ្ជើញចូលជួបសម្តែងការគួរសមចំពោះ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** នៅរសៀលថ្ងៃទី៨ ខែធ្នូ។ នៅក្នុងជំនួបនេះ ថ្នាក់ដឹកនាំទាំងពីរបានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះការរីកចម្រើន នៃទំនាក់ទំនងទ្វេភាគីដ៏ល្អប្រសើរ ដែលបាននាំមកនូវផលប្រយោជន៍ជាក់ស្តែងសម្រាប់ប្រទេសទាំងពីរ។ ឯកឧត្តមទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើឱ្យស៊ីជម្រៅបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ស្របតាមស្មារតីនៃ "ភាពជាអ្នកជិតខាងល្អ មិត្តភាពប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង"។

នៅក្នុងឱកាសកិច្ចប្រជុំJCលើកទី២១ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង **ឯកឧត្តម ឡេ ហ័យជុង** បានជម្រាបជូនគ្នាទៅវិញទៅមកអំពីការវិវឌ្ឍថ្មីៗនៃប្រទេសរៀងៗខ្លួន និងបានពិភាក្សាអំពីវិធានការណ៍នានា យ៉ាងស៊ីជម្រៅ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ។ ឯកឧត្តម រដ្ឋមន្ត្រីទាំងពីរបានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាព ដែលសម្រេចបានលើគ្រប់វិស័យ ចាប់តាំងពីកិច្ចប្រជុំJC លើកទី២០ និងបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាក្នុងការពង្រឹងភាពជាដៃគូយូរអង្វែងរវាងប្រទេសទាំងពីរ ។

**អំពីកិច្ចសហប្រតិបត្តិការនយោបាយ** ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់ពីសារៈសំខាន់នៃការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងជាញឹកញាប់ រវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិនៃប្រទេសទាំងពីរ ដើម្បីពង្រឹងចំណងមិត្តភាព និងសាមគ្គីភាពយូរអង្វែង។ ភាគីទាំងពីរបានអបអរសាទរចំពោះលទ្ធផលផ្លែផ្កានៃដំណើរទស្សនកិច្ចទៅវិញទៅមក រួមមានទស្សនកិច្ចផ្លូវរដ្ឋរបស់**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នៅប្រទេសវៀតណាម ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ការអញ្ជើញចូលរួមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៥០ នៃការរំដោះភាគខាងត្បូង និងការបង្រួបបង្រួមជាតិ នៅទីក្រុងហូជីមិញ ក្នុងខែមេសា ឆ្នាំ២០២៥ និងខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងឯករាជ្យជាតិរបស់វៀតណាម នៅរដ្ឋធានីហាណូយកាលពីខែកញ្ញា ឆ្នាំ២០២៥; ទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម តូ ឡឹម** ប្រធានរដ្ឋវៀតណាម មកកាន់ប្រទេសកម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០២៤ និងទស្សនកិច្ចផ្លូវការរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសវៀតណាម ក្នុងខែធ្នូ ឆ្នាំ២០២៣។

**ពាក់ពន្ធ័នឹងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ និងធនធានមនុស្ស** ភាគីទាំងពីរបានឯកភាពបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការតាមរយៈការរៀបចំអនុស្សរណៈនៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ រវាងក្រសួងអប់រំ យុវជន និងកីឡាកម្ពុជា និងក្រសួងអប់រំ និងបណ្តុះបណ្តាលវៀតណាម សម្រាប់រយៈពេល៥ឆ្នាំខាងមុខ ( ឆ្នាំ២០២៦-២០៣០ ) ដើម្បីជំនួសអនុស្សរណៈដែលមានបច្ចុប្បន្ន។

ភាគីទាំងពីរទទួលស្គាល់ថា **កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច** នៅតែជាអាទិភាពមួយក្នុងចំណោមអាទិភាពនានានៃកិច្ចសហប្រតិបត្តិការទ្វេភាគី ហើយបានឯកភាពបន្តធ្វើការយ៉ាងជិតស្និទ្ធ ក្នុងការជំរុញការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគី ដើម្បីសម្រេចបានគោលដៅពាណិជ្ជកម្មចំនួន ២០ពាន់លានដុល្លារអាម៉េរិក នាពេលខាងមុខតាមការសម្រេចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។

ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរបានផ្តល់អាទិភាពលើកិច្ចសហប្រតិបត្តិការវិនិយោគនៅតំបន់ព្រំដែន ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅតំបន់ជនបទនៃប្រទេសកម្ពុជា និងវៀតណាម។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការសហគ្រាសធុនតូច និងមធ្យមតាមរយៈសេវាកម្មអភិវឌ្ឍន៍អាជីវកម្ម និងការចែករំលែកឧត្តមានុវត្តន៍ ដោយផ្តោតលើគំរូអាជីវកម្មឌីជីថល នវានុវត្តន៍ប្រកបដោយបរិយាបន្ន ការបង្កើនផលិតភាព និងការរៀបចំបណ្តុំសហគ្រាសធុនតូច និងមធ្យម ។ ភាគីទាំងពីរបានឯកភាពសិក្សារួមគ្នាអំពី "យន្តការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងស្ថានភាពថ្មី ដើម្បីតភ្ជាប់សេដ្ឋកិច្ចកម្ពុជា និងវៀតណាមឱ្យកាន់តែជិតស្និទ្ធ" ដោយផ្អែកលើ "ផែនការមេស្តីពីការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-វៀតណាម ដល់ឆ្នាំ២០៣០"។

**នៅក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ភាគីទាំងពីរបានឯកភាពជំរុញការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិធានការអនាម័យ និងភូតគាមអនាម័យ ព្រមទាំងពន្លឿនការពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងអនុវិស័យកៅស៊ូធម្មជាតិ។

**អំពីកិច្ចសហប្រតិបត្តិការវប្បធម៌** ភាគីទាំងពីរបានអបអរសាទរចំពោះការរៀបចំដោយជោគជ័យនូវសប្តាហ៍វប្បធម៌កម្ពុជា នៅវៀតណាម ក្នុងឆ្នាំ២០២៥ និងបានសម្តែងការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរួមគ្នារៀបចំសប្តាហ៍វប្បធម៌វៀតណាម នៅកម្ពុជា ក្នុងឆ្នាំ២០២៦។ ដើម្បីធ្វើឱ្យកិច្ចសហប្រតិបត្តិការក្នុងវិស័យនេះឱ្យកាន់តែស៊ីជម្រៅ ភាគីទាំងពីរបានលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធអនុវត្តនផែនការសហប្រតិបត្តិការ ស្តីពីវប្បធម៌ និងសិល្បៈ រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈកម្ពុជា និងក្រសួងវប្បធម៌ កីឡា និងទេសចរណ៍វៀតណាម សម្រាប់ឆ្នាំ២០២៣-២០២៧ ឱ្យមានប្រសិទ្ធភាព។

**អំពីកិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូន** ភាគីទាំងពីរបានឯកភាពរៀបចំគម្រោងដឹកជញ្ជូនតភ្ជាប់កម្ពុជា និងវៀតណាម ជាពិសេសច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ដើម្បីជំរុញការដឹកជញ្ជូនទំនិញ និងអ្នកដំណើរឆ្លងកាត់ព្រំដែននៅក្នុងតំបន់។ ភាគីទាំងពីរបានឯកភាពពន្លឿនការពិភាក្សាលើចំណុចតភ្ជាប់ផ្លូវល្បឿនលឿន ភ្នំពេញ-បាវិត-ហូជីមិញ-ម៉ុកបៃ និងបានឯកភាពសិក្សារួមគ្នាអំពីលទ្ធភាពបង្កើតផ្លូវដែកតភ្ជាប់ភ្នំពេញ-បាវិត-ម៉ុកបៃ-ហូជីមិញ។

**អំពីកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល** ភាគីវៀតណាមបានឯកភាពបន្តផ្តល់សេវាថែទាំសុខភាព និងការព្យាបាលសម្រាប់អ្នកជំងឺកម្ពុជាដូចគ្នានឹងពលរដ្ឋវៀតណាម នៅក្នុងមន្ទីរពេទ្យរដ្ឋធំៗនៅទីក្រុងហូជីមិញ និងខេត្តជាប់ព្រំដែន ស្របតាមគម្រោងបង់ប្រាក់របស់មន្ទីរពេទ្យវៀតណាម សម្រាប់អ្នកជំងឺដែលគ្មានប័ណ្ណធានារ៉ាប់រង និងស្របតាមបទប្បញ្ញត្តិរបស់វៀតណាម។

**អំពីកិច្ចសហប្រតិបត្តិការសន្តិសុខ** ភាគីទាំងពីរបានបញ្ជាក់អំពីភាពចាំបាច់សម្រាប់ពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់រួមមានបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន ឧក្រិដ្ឋកម្មសេដ្ឋកិច្ច ការជួញដូរមនុស្ស អន្តោប្រវេសន៍ខុសច្បាប់ ឧក្រិដ្ឋកម្មបច្ចេកវិទ្យា ការកាប់ឈើ និងការដឹកជញ្ជូនឈើខុសច្បាប់ និងឧក្រិដ្ឋកម្មធនធានធម្មជាតិ ។ ភាគីទាំងពីរក៏បានពិភាក្សាអំពីលទ្ធភាពនៃការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាសម្រាប់អ្នកញៀនគ្រឿងញៀន នៅតំបន់ភាគខាងកើតនៃប្រទេសកម្ពុជា។

**អំពីកិច្ចសហប្រតិបត្តិការការពារជាតិ** ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការ និងពង្រឹងទំនាក់ទំនងរវាងកងទ័ពនៃប្រទេសទាំងពីរ ។ ឯកឧត្តមរដ្ឋមន្ត្រីទាំងពីរបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការរក្សាយន្តការសន្ទនាគោលនយោបាយការពារជាតិ និងឯកភាពអនុវត្តលិខិតូបករណ៍នានា នៃសហប្រតិបត្តិការដែលមានស្រាប់ឱ្យមានប្រសិទ្ធភាព រួមមានពិធីសារស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងអនុស្សរណៈយោគយល់ស្តីពីការបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការការពារព្រំដែន ដើម្បីរួមចំណែកក្នុងការរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ ។ ភាគីទាំងពីរក៏បានប្តេជ្ញាពង្រឹងការបណ្តុះបណ្តាលកងទ័ពរយៈពេលខ្លី និងរយៈពេលវែង ឱ្យកាន់តែស៊ីជម្រៅ ដើម្បីបំពេញសេចក្តីត្រូវការលើវិស័យការពារជាតិដែលកំពុងមានការវិវត្ត។

ភាគីទាំងពីរក៏បានឯកភាពធ្វើការជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិកម្ពុជា-ឡាវ-វៀតណាម រួមទាំងការបន្តកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិបីប្រទេស និងពិនិត្យលទ្ធភាពរៀបចំសកម្មភាពរួមសម្រាប់វិស័យការពារជាតិ និងយោធារវាងប្រទេសទាំងបី។

**ពាក់ពន្ធ័នឹងកិច្ចការព្រំដែន និងប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនគោក** រដ្ឋមន្ត្រីទាំងពីរបានសម្តែងនូវការសាទរចំពោះលទ្ធផលជាវិជ្ជមាននៃការខណ្ឌសីមា និងបោះបង្គោលព្រំដែន និងបានសម្តែងនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពន្លឿនការងារខណ្ឌសីមាក្នុងកំណាត់ខ្សែព្រំដែនដែលនៅសេសសល់ ព្រមទាំងបានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នានៅក្នុងការកសាងនូវព្រំដែនសន្តិភាព មិត្តភាព និងការអភិវឌ្ឍ ។ ភាគីទាំងពីរបានសាទរចំពោះពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវច្រកទ្វារអន្តរជាតិមីុនជ័យ (ព្រៃវែង) - តីនណាម (តេនិញ)

ក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ហើយបានឯកភាពបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ប៉ុស្តិ៍ត្រួតពិនិត្យនេះទៅកាន់តំបន់សេដ្ឋកិច្ចនៃប្រទេសនីមួយៗ ក្នុងគោលបំណងសម្រួលការធ្វើដំណើរឆ្លងកាត់ព្រំដែន ការដឹកជញ្ជូនទំនិញរវាងប្រទេសទាំងពីរ និងរវាងខេត្តព្រៃវែងនៃប្រទេសកម្ពុជា និងខេត្តតៃនិញ នៃប្រទេសវៀតណាម។

ភាគីទាំងពីរបានពិភាក្សាយ៉ាងទូលំទូលាយអំពីកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យជាច្រើន រួមមាន បរិស្ថាន ធនធានទឹក និងឧតុនិយម ថាមពល ការគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ឧស្សាហកម្ម គយ អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន (ICT) ហិរញ្ញវត្ថុនិងធនាគារ ការគាំពារសង្គមកិច្ច កិច្ចសហប្រតិបត្តការលើវិស័យច្បាប់ និងតុលាការ និងកិច្ចការអធិការកិច្ច ។

រដ្ឋមន្ត្រីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈអំពីការវិវត្តនៅក្នុងតំបន់ និងអន្តរជាតិដែលជាការយកចិត្តទុកដាក់រួម ។ ថ្នាក់ដឹកនាំទាំងពីរបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញា ក្នុងការសម្របសម្រួលបញ្ហាតំបន់និង សកលឱ្យបានជិតស្និទ្ធ ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ និងស្ថិរភាព ហើយបានសន្យាថានឹងបន្តគាំទ្រគ្នាទៅវិញទៅមកទាំងក្នុងវេទិកាតំបន់ និងអន្តរជាតិ។

កិច្ចប្រជុំត្រូវបានបញ្ចប់ដោយការចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំលើកទី២១ នៃគណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (JC) និងបានឯកភាពគ្នារៀបចំកិច្ចប្រជុំJC កម្ពុជា-វៀតណាម លើកទី២២ នៅប្រទេសវៀតណាម ក្នុងឆ្នាំ២០២៦។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥